**ពាក្យស្លោក សម្រាប់ ពិធីទិវាជាតិ១២ធ្នូ២០១៧ ដែលនឹងប្រព្រឹត្តទៅ នៅសាលសន្និសីទ និងពិព័រណ៍កោះពេជ្រ**

ស្នើសុំការចូលរួមឧបត្ថម្ភគាំទ្រពីសាលារាជធានីភ្នំពេញ៖

បដា ៤០ សម្រាប់ ចងតាមដងវិថីសហភាពសូវៀត ពីព្រលានយន្តហោះ មក ដល់មហាវិថីព្រះនរោត្តម ដងមហាវិថី ព្រះនរោត្តម និងភ្ជាប់ទៅ មជ្ឈមណ្ឌល ពិពរណ៍ និងមហោស្រពកោះពេជ្រ ។

<u>តាមបណ្ដាខេត្ត</u> ៖

អាចជ្រើសរើសពាក្យស្លោកទាំងនេះ ប្រើប្រាស់ សម្រាប់ពិធី ឬផ្សព្វផ្សាយតាមបណ្ដាខេត្តនីមួយៗ ។

1. អបអរសាទរ! ទិវាជាតិ លើកទី១១ ប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ១២ធ្នូ ឆ្នាំ២០១៧! (២)
2. Congratulations! The Celebration of the 11th National Day on Anti-Human Trafficking, December 12, 2017!
3. រួមគ្នាបង្កើតប្រព័ន្ធសុវត្ថិភាព និងពង្រឹងការអនុវត្តច្បាប់ ដើម្បីការពារប្រជាពលរដ្ឋពីអំពើជួញដូរមនុស្ស
4. Together create safety net and enforce law practices for protecting our people from trafficking in persons
5. រួមគ្នាបង្ការទប់ស្កាត់! ជួយជនរងគ្រោះ! បង្ក្រាប និងផ្ដន្ទាទោសជនល្មើសឲ្យបានដាច់ខាត!
6. ពង្រឹងការគ្រប់គ្រងលំហូរទេសន្តរប្រវេសន៍មិនប្រក្រតីឆ្លងកាត់ព្រំដែន! បង្កើនជម្រើសការងារក្នុងស្រុក ដើម្បីសុវត្ថិភាពពលករ!
7. អំពើជួញដូរមនុស្ស គឺជាការរំលោភសិទ្ធិមនុស្ស យ៉ាងធ្ងន់ធ្ងរ!! Trafficking in persons is a grave Human Rights Violation!!
8. រាជរដ្ឋាភិបាលកម្ពុជា ប្រឆាំងដាច់ខាតអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ ជាពិសេស លើស្ត្រី និងកុមារ
9. សុវត្ថិភាពជាចម្បង! គិតឲ្យច្បាស់សិន កុំចាកចេញ ឆ្លងដែនដោយខុសច្បាប់!
10. អ្នកជាមនុស្សសំខាន់សម្រាប់គ្រួសារ និងប្រទេសជាតិ មិនមែនជាទំនិញសម្រាប់ ឧក្រិដ្ឋជនជួញដូរមនុស្សទេ!
11. ធ្វើការក្នុងស្រុកក៏សុខសប្បាយ! បើទៅធ្វើការឆ្ងាយក៏ត្រូវមានសុវត្ថិភាព និងសេចក្ដីថ្លៃថ្នូរ!
12. កម្ពុជា ជាព្រះរាជាណាចក្រអច្ឆរិយៈ! មានសម្បត្តិវប្បធម៌ និងធម្មជាតិស្រស់បំព្រង មិនមែនជាកន្លែងសម្រាប់ទេសចរណ៍ផ្លូវភេទទេ!
13. ជនណា ជួញដូរមនុស្ស និងរំលោភបំពានផ្លូវភេទលើកុមារ គឺជា ឧក្រិដ្ឋជន ដែលត្រូវផ្ដន្ទាទោសយ៉ាងធ្ងន់ធ្ងរ!
14. Trafficking in persons is a Crime, traffickers shall be punished seriously, according to Cambodian Law!
15. No Child Sex Tourism! No Child Sexual Abuse in Cambodia, Perpetrators shall be punished seriously!
16. កសិកម្ម ឧស្សាហកម្ម ពាណិជ្ជកម្ម សេវាកម្ម ទេសចរណ៍ ការងារ សំណង់នៅកម្ពុជា ត្រូវការអ្នក ដើម្បីអភិវឌ្ឍន៍ប្រទេសជាតិយើង!
17. **នាំគ្នាបង្កើនផលិតផលក្នុងស្រុកគ្រប់ប្រភេទ ប្រកបដោយគុណភាព សម្រាប់ស្វាគមន៍ទេសចរណ៍ដែលមកទស្សនាព្រះរាជាណាចក្រកម្ពុជាយើង!**
18. រួមគ្នាបញ្ឈប់ការជួញដូរមនុស្ស និងការកេងប្រវ័ញ្ចគ្រប់រូបភាព ដើម្បីកសាងអនាគតល្អ សម្រាប់ប្រជាជន និងប្រទេសជាតិយើង!
19. ជនងាយរងគ្រោះ និងជនរងគ្រោះ ត្រូវការជំនួយ និងការគាំទ្រពីយើងទាំងអស់គ្នា!
20. បុរស ស្ត្រី យុវវ័យ និងកុមារ ជាធនធានដ៏មានតម្លៃរបស់ជាតិ សូមចូលរួម ថែរក្សា ការពារ កុំឲ្យក្លាយជាកម្មវត្ថុរបស់ ឧក្រិដ្ឋជនជួញដូរមនុស្ស!
21. .រួមគ្នាលើកកម្ពស់សីលធម៌សង្គម និងការអនុវត្តច្បាប់ ដើម្បីលុបបំបាត់រាល់ទម្រង់នៃអំពើហិង្សា និងការកេងប្រវ័ញ្ចគ្រប់រូបភាព
22. ផ្ដន្ទាទោសយ៉ាងធ្ងន់ធ្ងរ! ដល់ជនទាំងឡាយណា ដែលជាមេខ្លោង អ្នកសមគំនិត អ្នកផ្ដល់មធ្យោបាយ ជួញដូរមនុស្ស និងធ្វើអាជីវកម្មផ្លូវភេទ

23. លុបបំបាត់រាល់ទម្រង់ធូន់ធ្ងរនៃពលកម្មកុមារ និងអាជីវកម្មផ្លូវភេទលើកុមារ ឬអនីតិជន នៅកម្ពុជា។
24. អ្នកធ្វើអាជីវកម្មផ្លូវភេទលើកុមារ នឹងត្រូវផ្តន្ទាទោសជាប់ពន្ធនាគារពី ៥ឆ្នាំ ទៅ១៥ឆ្នាំ។
25. បើបានឮ បានឃើញ ឬសង្ស័យថាមានអំពើរំលោភបំពាន ឬជួញដូរមនុស្ស សូមទាក់ទងលេខៈ **១១៧ ឬ ១១៨ ឬ ១២៨៨ ឬ ១២៩៩**